ទំនុកដំកើង១០៧-១០៩

# មហាវគ្គចោទិយកថា
# សេចក្តីសរសើរដល់ភាពបរិសុទ្ធនៃព្រះបន្ទូល
# ជំពូក១០៧-១៥០

ដូចខ្ញុំបានជម្រាបរួចមកហើយថា យើងចែកគម្ពីរទំនុកដំកើងជាប្រាំមហាវគ្គ យកតាមលំដាប់នៃកណ្ឌព្រះគម្ពីរបញ្ចកណ្ឌ។ ជំពូក១០៧ ចាប់ផ្តើមមហាវគ្គចោទិយកថា នៅក្នុងកណ្ឌព្រះគម្ពីរទំនុកដំកើង។ អ្នកប្រាជ្ញព្រះគម្ពីរមួយរូបនាមបណ្ឌិតហ្គែបីឡេន ធ្វើសេចក្តីកំណត់ហេតុយ៉ាងដូច្នេះថា "លោកម៉ូសេកត់ត្រាទុកគម្ពីរចោទិយកថា ដើម្បីរំឭកពីគ្រាដែលព្រះជាម្ចាស់ផ្តល់សេចក្តីមេត្តាករុណាដល់រាស្ត្ររបស់ទ្រង់ ពេលគេធ្វើដំណើរកាត់ទីវាលរហោស្ថានស្រុកម៉ូអាប់។ ក្រោយមករាស្ត្ររបស់ព្រះបានមកដល់ច្រកនាំចូលទៅទឹកដីសន្យា។ ទាក់ទងនឹងហេតុការណ៍ខាងលើ គម្ពីរទំនុកដំកើងមហាវគ្គចោទិយកថា រៀបរាប់ពីសាសន៍អ៊ីស្រាអែលសេសសល់ រស់ឆ្លងកាត់គ្រាមហាទុក្ខត្រូវធ្វើដំណើរចូលទៅទឹកដីសន្យាដែលព្រះជាម្ចាស់រៀបចំសម្រាប់សាសន៍នេះ។ ព្រះជាម្ចាស់មិនដែលបោះបង់ចោលរាស្ត្ររបស់ព្រះអង្គទេ។ ព្រះអង្គដឹកនាំគេ ព្រះអង្គជំនុំជំរះគេ ព្រះអង្គបណ្តោយអោយគេប្រព្រឹត្តតាមគំនិតល្ងង់ខ្លៅរបស់គេ តែព្រះអង្គថែរក្សា

គេ អោយគេរស់រានមានជីវិតតរៀងមក” *(បទបរិមាធិប្បាយទំនុកដំកើងទំព័រ៣៩៩)*។

ពួកអ្នកជឿដល់ព្រះជាម្ចាស់គ្រប់ជំនាន់ ទទួលបទពិសោធន៍ដូចជាសាសន៍អ៊ីស្រាអែលឆ្លងកាត់ក្នុងគម្ពីរចោទិយកថា។ ដោយហេតុនេះ មហាវគ្គចោទិយកថានៃព្រះគម្ពីរទំនុកដំកើង អាចយកមកអនុវត្តក្នុងបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកអ្នក ហើយនិងរូបខ្ញុំផ្ទាល់។

# ជំពូក ១០៧

*ចំណងជើង ភាពល្អនៃព្រះជាម្ចាស់*

គម្ពីរទំនុកដំកើងជំពូក១០៧ មានគេយល់ច្រឡំជាច្រើនដែរ។ មូលហេតុដែលធ្វើឱ្យគេយល់ច្រឡំ ពីព្រោះជំពូកនេះ ជាបទទំនាយសម្រាប់សាសន៍អ៊ីស្រាអែលក្នុងគ្រាអានាគត។ ជំពូក១០៧ ត្រូវបកស្រាយអោយត្រូវតាមសំនួនវោហារនិងបរិបទ។ ជំពូក១០៧ សរសេរសម្រាប់ជាការអនុវត្តន៍របស់រាស្ត្រព្រះអង្គគ្រប់ជំនាន់ផង ជាបទទំនាយសម្រាប់សាសន៍យូដា នៅក្នុងគ្រាអនាគតផងដែរ។ នៅគ្រាអានាគត សាសន៍យូដាច្រៀងតម្កើងសរសើរដល់ព្រះជាម្ចាស់ ព្រោះគេមានឯកសិទ្ធិចូលទឹកដីសន្យាម្តងទៀត។ ប៉ុន្តែ ទោះបីសេចក្តីទាំងនេះជាបទទំនាយសម្រាប់គ្រាអនាគតក៏ដោយ យើងជាពួកបរិសុទ្ធរបស់ព្រះជាម្ចាស់អាចប្រើខគម្ពីរនេះសម្រាប់ ជាព្រះពរដល់ចិត្តយើងគ្រប់គ្នាបានដែរ។

គម្ពីរទំនុកដំកើងជំពូក១០៧ ចែកជាបួនវគ្គ ហើយក្នុងមួយវគ្គមានបទបន្ទរដូចគ្នាមានចំនួនបីដង។

# ព្រះជាម្ចាស់ទំនុកបម្រុងរាស្ត្រទ្រង់

**១ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរស**
**នៃទ្រង់ស្ថិតស្ថេរនៅជានិច្ច ២គួរឱ្យពួកអ្នកដែលព្រះយេហូវ៉ាបាន**
**ប្រោសលោះបានថាដូច្នេះដែរ គឺអស់អ្នកដែលទ្រង់បានលោះ ឱ្យ**
**រួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវនោះ (ទំនុកដំកើង១០៧:១-២)។**

"គួរឱ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះបានថាដូច្នេះ"។ យើងជាគ្រីស្ទបរិស័ទ ត្រូវចេះពោលដូច្នេះថា "ព្រះជាម្ចាស់ទ្រង់ល្អ!" ពួកអ្នកដែលព្រះយេហូវ៉ាបានលោះត្រូវចេះនិយាយយ៉ាងដូច្នេះថា "ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច"។ គ្រីស្ទបរិស័ទមិនត្រូវដាក់គូទបើកមាត់និយាយដើមគ្នា ឬរិះគន់គ្នាទៅវិញទៅមកទេ។ គ្រីស្ទបរិស័ទត្រូវបើកមាត់និយាយដូច្នេះថា "ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អសេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច"។ យើងត្រូវបើកមាត់ប្រាប់មនុស្សលោកថា "ព្រះជាម្ចាស់មានព្រះទ័យសប្បុរស"។ បើយើងមិនចេះនិយាយថា ព្រះយេហូវ៉ាទ្រង់ល្អទេ មនុស្សក្នុងលោកដែលមិនស្គាល់ព្រះអម្ចាស់យេស៊ូវ សប្បាយចិត្តណាស់ ពីព្រោះគេឃើញថាបងប្អូនអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ ចេះដៀលត្មះព្រះអង្គដែរ។ មនុស្សបាត់បង់តែងជេរប្រទេច ដៀលត្មះដល់ព្រះជាម្ចាស់ឥតដឹងគុណដល់ព្រះអង្គ សូម្បីខ្យល់ដង្ហើមដែល

គេដកទឹក ដែលគេទទួលទាន សុខភាពល្អ គេមិនបានដឹងគុណដល់ព្រះជាម្ចាស់ ថា ទ្រង់ប្រទានដល់គេ។ គំនិតរបស់មនុស្សមានបាប គិតថា ព្រះជាម្ចាស់មានព្រះទ័យអាក្រក់ណាស់។ អ្នកខ្លះយល់ថា ព្រះជាម្ចាស់តាមបំផ្លាញគេ បើគេធ្វើអំពើអាក្រក់អ្វីមួយ។ ខ្លះគិតថា ព្រះជាម្ចាស់មានកិរិយាកាចសាហាវយង់ឃ្នង មិនអោយមនុស្សណាទៅជិតទ្រង់បានទេ បើសង់ផ្ទះចំកន្លែងព្រះក្រឡេក អ្នកនោះនឹងត្រូវអន្តរាយដល់ជីវិតរបស់ខ្លួនជាដើម។ ចំពោះអ្នកដែលមានចិត្តគិតពីព្រះ គេយល់ថា ព្រះជាម្ចាស់មានកិរិយាសាហាវយង់ឃ្នង។ ចំពោះអ្នកដែលមិនគិតថាមានព្រះ គេយល់ថា កម្មវិធីអភិវឌ្ឍន៍សង្គម សិក្សាអប់រំ ឧស្សាហកម្ម ឬកម្មវិធីមនុស្សធម៌ល្អគ្រប់គ្រាន់ សម្រាប់ដោះស្រាយសេចក្តីទុក្ខលំបាករបស់មនុស្សលោក។ ប៉ុន្តែ បើតាមការអនុវត្តន៍ជាក់ស្តែងវិញ សូម្បីកម្មវិធីកាត់បន្ថយភាពក្រីក្រ ត្រូវយកអ្នកក្រធ្វើជាទុនសម្រាប់ប្រយោជន៍ខ្លួនដែរ។ មនុស្សបាត់បង់គ្មានចិត្តទទួលស្គាល់សេចក្តីល្អរបស់ព្រះជាម្ចាស់ សូម្បីតែបន្តិចបន្តួចសោះក៏គ្មានដែរ។ អ្នកដែលអាចនិយាយថា "ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច" មានតែពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះរួចពីអំពើបាបតែប៉ុណ្ណោះ។ ព្រះយេហូវ៉ាទ្រង់ល្អ ទ្រង់មិនមែនល្អតាមការសន្មត្តិរបស់មនុស្សលោកទេ។ ម្យ៉ាងទៀត ព្រះអង្គមិនមែនល្អដោយមនុស្សលោកប្រើភស្តុតាងណាមួយបញ្ជាក់ក៏គ្មានដែរ។ ព្រះអម្ចាស់ទ្រង់ល្អ មិនមែនដោយសារទំនៀមទម្លាប់របស់ជាតិសាសន៍ណា ឬជាពាក្យស្លោកណាដែលមនុស្សលើកមកនាំគ្នានិយាយឡើយ។ មិនតែប៉ុណ្ណោះ ព្រះអម្ចាស់ទ្រង់ល្អ មិនមែនជាការឃោសនារបស់អ្នកកាន់

សាសនាគ្រីស្ទក៏ទេដែរ។ ព្រះយេហូវ៉ាទ្រង់ល្អ ពីព្រោះព្រះអង្គពិតជាល្អចំពោះមនុស្សលោកគ្រប់ៗរូប។

> **ហើយប្រមូលមកពីគ្រប់ទាំងស្រុក គឺពីទិសខាងកើត ទិសខាងលិច ទិសខាងជើង ហើយទិសខាងត្បូងផង (ទំនុកដំកើង១០៧:៣)។**

ព្រះយេហូវ៉ាទ្រង់នឹងប្រមូលរាស្ត្រទ្រង់ ដែលរស់នៅរាត់រាយពីទិសខាងកើត ខាងលិច ខាងជើង និងខាងត្បូង។ តើរាស្ត្រព្រះអង្គរស់នៅខ្ចាត់ខ្ចាយគ្រប់ទិសទីជាអ្នកណា? ខគម្ពីរខាងលើ ព្រះអង្គមានបន្ទូលពីសាសន៍អ៊ីស្រាអែល។

> **[៤]គេបានដើរសាត់អណ្តែត តាមផ្លូវស្ងាត់ឈឹងក្នុងទីរហោស្ថាន គេ**
> **រកទីក្រុងណាដែលល្មមអាស្រ័យនៅមិនបានឡើយ [៥]ព្រលឹងគេក៏**
> **ហេវទៅ ដោយស្រេកឃ្លាន [៦]គ្រានោះ គេបានអំពាវនាវដល់**
> **ព្រះយេហូវ៉ា ដោយសេចក្តីវេទនារបស់គេ ហើយទ្រង់ក៏ប្រោស**
> **ឱ្យរួចពីសេចក្តីលំបាកនោះ [៧]ទ្រង់បាននាំគេតាមផ្លូវត្រង់វិញ ដើម្បី**
> **ឱ្យគេចូលដល់ទីក្រុងដែលអាស្រ័យនៅបាន (ទំនុកដំកើង ១០៧:៤-៧)។**

គម្ពីរទំនុកដំកើងជំពូក១០៧ ជាកិច្ចចាប់ផ្តើមមហាវគ្គចោទិយកថានៃគម្ពីរទំនុកដំកើង។ មហាវគ្គនេះជាសេចក្តីសរសើរដល់ភាពបរិសុទ្ធនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅក្នុងគម្ពីរចោទិយកថា ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅកាន់សាសន៍អ៊ីស្រាអែលថា បើគេមិនព្រមបោះបង់ចោលអំពើបាបរបស់គេទេ ព្រះអង្គនឹងវាយកំចាយគេអោយទៅតាំងទីលំនៅ នៅគ្រប់នគរ។ ចោទិយកថា២៨:៦៤-៦៥សម្តែងថា "ព្រះយេហូវ៉ាទ្រង់នឹងកំចាត់កំចាយឯង ឱ្យទៅនៅក្នុងគ្រប់ទាំងសាសន៍ ពីចុងផែនដីម្ខាងរហូតដល់ចុងផែនដីម្ខាង នៅទីនោះឯងនឹងគោរពប្រតិបត្តិដល់ព្រះដទៃធ្វើពីឈើ ហើយនឹងថ្ម ដែលឯងនឹងពួកឰយុកោឯងមិនដែលស្គាល់សោះ នៅក្នុងសាសន៍ទាំងនោះ ឯងនឹងរកសេចក្តីស្រណុកមិនបាន ហើយបាតជើងឯងមិនចេះបានសំរាកឡើយ គឺនៅទីនោះព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យចិត្តឯងញ័ររន្ធត់ ឱ្យភ្នែកឯងស្រវាំងទៅ ហើយឱ្យមានគំនិតព្រួយលំបាកដែរ"។ នៅលើលោកនេះ នៅគ្រប់ទ្វីបទាំងអស់មានសាសន៍អ៊ីស្រាអែលរស់នៅ។ ហេតុអ្វី? ព្រះគម្ពីរសម្តែងថា មកពីសាសន៍អ៊ីស្រាអែលមិនស្តាប់បង្គាប់ដល់ព្រះជាម្ចាស់។ សាសន៍អ៊ីស្រាអែលរស់នៅបែកខ្ញែកគ្នារហូតដល់គ្រាមួយនៅក្នុងពេលអនាគត។ ពេលនោះ ព្រះអង្គនឹងប្រមូលរាស្ត្ររបស់ទ្រង់ទាំងអស់ អោយត្រឡប់មករស់នៅក្នុងទឹកដីអ៊ីស្រាអែលវិញ។ ហេតុការណ៍នេះជារូបភាពជាក់ស្តែងសម្តែងពីការទំនុកបម្រុងរបស់ព្រះជាម្ចាស់ចំពោះរាស្ត្រទ្រង់។ សេចក្តីពិតខាងលើ ត្រូវនឹងដំណើរជីវិតរបស់យើងគ្រប់គ្នាដែរ។ កាលយើងកំពុងវង្វេងបាត់បង់ក្នុងទីរហោស្ថាននៃជីវិត ព្រះជាម្ចាស់លូកព្រះហស្តព្រះអង្គទៅកៀងប្រមូលយើង អោយយើងបែរមកទទួលជឿ

ព្រះអម្ចាស់យេស៊ូវ ដើម្បីអោយបានទទួលសេចក្តីសង្គ្រោះ។ បើលោកអ្នកចង់ចូលមកព្រះអង្គ ទទួលយកសេចក្តីសង្គ្រោះ ព្រះអង្គពិតជាប្រទានអោយលោកអ្នក។ ព្រះជាម្ចាស់ទំនុកបម្រុងដល់រាស្ត្ររបស់ទ្រង់។ ព្រះអង្គមិនទាន់ឈប់គិតគូរពីសាសន៍អ៊ីស្រាអែល ព្រះអង្គមិនបានឈប់គិតគូរពីយើងរាល់គ្នា ដែលកំពុងរស់នៅសព្វថ្ងៃលើលោកសន្និវាសរបស់ព្រះអង្គនេះដែរ។

## ព្រះជាម្ចាស់អត់ទោសបាបដល់មនុស្សលោក

**ឱសូមឱ្យមនុស្សទាំងឡាយសរសើរដល់ព្រះយេហូវ៉ា ដោយព្រោះសេចក្តីសប្បុរសរបស់ទ្រង់ ហើយដោយព្រោះអស់ទាំងការអស្ចារ្យ ដែលទ្រង់បានប្រោសដល់មនុស្សជាតិ (ទំនុកដំកើង ១០៧:៨)។**

ខខាងលើ ជាបទបន្ទរ។ ព្រះជាម្ចាស់អត់ទោសអំពើបាបរបស់មនុស្សលោក។ ព្រះអង្គរំដោះមនុស្សដែលជាប់ទោសអោយមានសេរីភាពឡើងវិញ។ ហេតុការណ៍នេះកើតឡើងនៅពេលសាសន៍អ៊ីស្រាអែលត្រូវរស់ឆ្លងកាត់គ្រាមហាទុក្ខ។ នៅពេលនោះព្រះជាម្ចាស់ទ្រង់យាងមក រំដោះរាស្ត្រទ្រង់អោយត្រឡប់ចូលទៅនៅក្នុងទឹកដីសន្យាវិញ។ ឯទឹកដីសន្យារបស់សាសន៍អ៊ីស្រាអែល គឺជាទឹកដីដែលតាំងនៅមជ្ឈិមបូព៌ាក្នុង

ពេលសព្វថ្ងៃនេះ។

> **ឯអស់អ្នកដែលអង្គុយនៅទីងងឹត ហើយក្នុងម្លប់នៃសេចក្តីស្លាប់ ជាពួកអ្នកដែលជាប់មានសេចក្តីវេទនា ហើយនឹងចំណងច្រវាក់ (ទំនុកដំកើង១០៧:១០)។**

អ្នកជាប់មន្ទីរឃុំឃាំង គ្មានអ្វីជាទីសង្ឃឹមសម្រាប់ខ្លួនឡើយ។

> **១៤ទ្រង់បាននាំគេចេញពីទីងងឹត នឹងម្លប់នៃសេចក្តីស្លាប់ ព្រមទាំង**
> **បណ្តាច់ចំណងគេផង ១៥ឱសូមឱ្យមនុស្សទាំងឡាយសរសើរដល់**
> **ព្រះយេហូវ៉ា ដោយព្រោះសេចក្តីសប្បុរសរបស់ទ្រង់ ហើយដោយ**
> **ព្រោះអស់ទាំងការអស្ចារ្យ ដែលទ្រង់បានប្រោសដល់មនុស្សជាតិ**
> **១៦ដ្បិតទ្រង់បានទំលាយអស់ទាំងទ្វារលង្ហិន ហើយបំបាក់រនុកដែក**
> **ដែរ (ទំនុកដំកើង១០៧:១៤-១៦)។**

ព្រះជាម្ចាស់តែងតែរំដោះរាស្ត្រទ្រង់ ដែលគេយកទៅដាក់ទោសដោយអយុតិធម៌។ ព្រះអង្គបានដោះលោកពេត្រុស សាវ័កប៉ុល និងលោកសីឡាស ចេញពីមន្ទីរឃុំឃាំង។ ព្រះអង្គរំដោះយើងអោយរួចពីគុកកម្មនៃអំពើបាបទាំងឡាយទាំងពួង បើ

យើងព្រមជឿដល់ព្រះអម្ចាស់យេស៊ូវ។ ចំពោះមនុស្សទូទៅ ព្រះអង្គមានព្រះហឫទ័យចង់អត់ទោសដល់គេ។ ព្រះជាម្ចាស់ពិតជាមានព្រះហឫទ័យចង់អត់ទោសដល់មនុស្សគ្រប់រូប។ តើធ្វើដូចម្តេច ដើម្បីអោយទទួលបានសេចក្តីអត់ទោសពីព្រះជាម្ចាស់? យើងត្រូវទទួលយកទឹកចិត្តសប្បុរសរបស់ព្រះអង្គ ទើបយើងអាចទទួលបាននូវការអត់ទោសពីទ្រង់។ មានរឿងពិតមួយពី បុរសម្នាក់ជាប់គុកនៅរដ្ឋ ផិនស៊ីលវ៉េនីញ៉ាសហរដ្ឋអាមេរិក។ ចៅហ្វាយខេត្តរដ្ឋនោះ ផ្តល់ការលើកលែងទោសដល់បុរសមួយរូប។ ជននោះមិនព្រមទទួលការលើកលែងទោសលោកអភិបាលខេត្តទេ។ អាជ្ញាធរពន្ធនាគារមិនដឹងជាធ្វើយ៉ាងម៉េច បានជាចាំបាច់ត្រូវវើរឿងក្តីបញ្ជូនទៅតុលាការ។ នីតិតុលាការត្រូវកាត់ទោសអោយបុរសនោះជាប់គុកតទៅទៀត ទើបមានសិទ្ធិទុកជននោះនៅក្នុងពន្ធនាគារ។ នៅក្នុងករណីនេះ បើជនដែលជាប់គុកទទួលការលើកលែងទោសពីអភិបាលខេត្ត ជននោះមានសេរីភាព។

ព្រះអម្ចាស់ជាព្រះនៃយើង មានព្រះហឫទ័យចង់ផ្តល់ការលើកលែងទោសដល់លោកអ្នក។ ព្រះអង្គបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ព្រះនាមព្រះអម្ចាស់យេស៊ូវអោយមកសុគតនៅលើឈើឆ្កាងជំនួសអំពើបាបរបស់លោកអ្នក។ ទ្រង់រស់ឡើងវិញ ដើម្បីរាប់លោកអ្នកថាជាជនសុចរិត។ លោកអ្នកត្រូវទទួលការអត់ទោសពីព្រះជាម្ចាស់ ទើបមានសេរីភាព។ តើលោកអ្នកមានចិត្តចង់ទទួលការអត់ទោសពីព្រះជាម្ចាស់ដែរឬទេ? បើលោកអ្នកបានទទួលការអត់ទោសរួចហើយ តើលោកអ្នកកំពុងទទួលសេរីភាពរួចពីការជិះជាន់នៃអំពើបាបផ្ទាល់ខ្លួនរបស់លោកអ្នកហើយឬនៅ?

សេចក្តីដែលសម្តែងនៅក្នុងខខាងលើ ជាការសម្តែងព្រះគុណរបស់ព្រះជាម្ចាស់ ចំពោះសាសន៍អីស្រាអែលនៅគ្រាអនាគត។ អ្នកដែលត្រូវរស់ឆ្លងកាត់គ្រាមហាទុក្ខ ប្រៀបឧបមាដូចជាអ្នករស់នៅក្នុងគុក។ ព្រះជាម្ចាស់នឹងយាងទៅរំដោះគេអោយរួចពីទុក្ខ ហើយបញ្ជូនគេអោយទៅនៅទឹកដីសន្យា ដែលព្រះអង្គរៀបចំទុកសម្រាប់គេវិញ។

## ព្រះជាម្ចាស់ការពាររាស្ត្រទ្រង់

**ឱសូមឱ្យមនុស្សទាំងឡាយសរសើរដល់ព្រះយេហូវ៉ា ដោយព្រោះសេចក្តីសប្បុរសរបស់ទ្រង់ ហើយដោយព្រោះអស់ទាំងការអស្ចារ្យ ដែលទ្រង់ប្រោសដល់មនុស្សជាតិ (ទំនុកដំកើង ១០៧:២១)។**

ខខាងលើ ជាសេចក្តីបន្ទរ។

**ដូច្នេះ គួរឱ្យគេថ្វាយដង្វាយនៃសេចក្តីអរព្រះគុណ ហើយប្រកាសពីស្នាដៃនៃទ្រង់ ដោយចំរៀងអរសប្បាយចុះ (ទំនុកដំកើង ១០៧:២២)។**

ព្រះអង្គសព្វព្រះហឫទ័យចង់អោយយើង នាំតង្វាយនៃការសរសើរ និងតង្វាយនៃការអរព្រះគុណ ពេលយើងចូលទៅចំពោះទ្រង់។ គម្ពីរហេព្រើរ១៣:១០-១៥ បញ្ជាក់ពីដំណើរនោះថា "យើងរាល់គ្នាមានអាសនា១ ដែលពួកអ្នកបំរើក្នុងរោងឧបោសថ គេគ្មានច្បាប់នឹងចូលមកបរិភោគពីអាសនានោះទេ ដ្បិតឯសត្វទាំងប៉ុន្មានដែលសំដេចសង្ឃនាំយកឈាម ចូលទៅក្នុងទីបរិសុទ្ធ ដោយព្រោះបាបនោះត្រូវដុតនៅខាងក្រៅទីដំឡើងត្រសាលវិញ ដូច្នេះព្រះយេស៊ូវទ្រង់ក៏បានរងទុក្ខ នៅខាងក្រៅទ្វារក្រុងដែរ ដើម្បីនឹងញែកប្រជាជនឱ្យបរិសុទ្ធ ដោយសារព្រះលោហិតនៃអង្គទ្រង់ ហេតុនោះបានជាត្រូវឱ្យយើងរាល់គ្នាចេញទៅឯទ្រង់ នៅខាងក្រៅទីដំឡើងត្រសាលដែរ ទាំងផ្ទុកសេចក្តីដំនៀលរបស់ទ្រង់ចុះ ដ្បិតនៅស្ថាននេះ យើងរាល់គ្នាគ្មានទីក្រុងណាដែលស្ថិតនៅជាប់ជានិច្ចទេ តែយើងកំពុងតែស្វែងរកក្រុងនោះដែលត្រូវមក ដូច្នេះត្រូវឱ្យយើងរាល់គ្នាថ្វាយពាក្យសរសើរ ដោយសារទ្រង់ ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់"។

លោកអ្នកមិនចាំបាច់រងចាំដល់ពេលទៅព្រះវិហារ ទើបអាចថ្វាយតង្វាយចំពោះទ្រង់ទេ។ បើយ៉ាងដូច្នោះ លោកអ្នកពិតជាទៅថ្វាយតង្វាយនៃការសរសើរដល់ព្រះជាម្ចាស់តែបបូរមាត់តែប៉ុណ្ណោះ។ យើងអាចថ្វាយតង្វាយ ជាកិរិយាសរសើរ និងកិរិយាអរព្រះគុណដល់ព្រះជាម្ចាស់រៀងរាល់វិនាទីក្នុងជីវិតយើង។ ក្នុងវិនាទីនេះ ព្រះជាម្ចាស់ដោះលោកអ្នកអោយមានសេរីភាពពីអំពើបាប ដែលលោកកំពុងតែប្រព្រឹត្ត។ មិនតែប៉ុណ្ណោះទ្រង់រក្សាលោកអ្នកអោយនៅតែមានភាពបរិសុទ្ធជានិច្ច។

**២៣ឯពួកអ្នកដែលចុះនាវាដើរផ្លូវសមុទ្រ ជាអ្នកដែលរកស៊ីទទួលការតាមផ្លូវទឹកធំ ២៤ពួកនោះគេឃើញអស់ទាំងការនៃព្រះយេហូវ៉ា នឹងការអស្ចារ្យរបស់ទ្រង់នៅទីជំរៅ (ទំនុកដំកើង ១០៧:២៣-២៤)។**

សេចក្តីខាងលើ សម្តែងពីពួកអ្នករកស៊ីតាមផ្លូវសមុទ្រ។ ជំនាន់ដើមអ្នកធ្វើដំណើររកស៊ីតាមសំពៅ មិនដែលគិតថាខ្លួនអាចមានជីវិតឆ្លងមកដល់ត្រើយវិញទេ។ ដូច្នេះហើយ បានជាពេលគេចេញធ្វើដំណើរទៅ គេទូលថ្វាយដំណើររបស់គេដាច់ដល់ព្រះជាម្ចាស់ អោយទ្រង់ការពារថែរក្សា និងនាំគេអោយមកដល់ច្រាំងវិញដោយសុវត្ថិភាព។ ការប្រគល់ជីវិត ប្រគល់ខ្លួនដាច់ដល់ព្រះជាម្ចាស់ក្នុងគ្រាមានទុក្ខលំបាក ជាកិរិយាសម្តែងថា ជននោះទុកចិត្តដល់ព្រះជាម្ចាស់ដោយឥតសង្ស័យ។

## ព្រះជាម្ចាស់ពេញព្រះហឫទ័យនឹងរាស្ត្រទ្រង់

**ឱសូមឱ្យមនុស្សទាំងឡាយសរសើរដល់ព្រះយេហូវ៉ា ដោយព្រោះសេចក្តីសប្បុរសរបស់ទ្រង់ ហើយដោយព្រោះអស់ទាំងការអស្ចារ្យដែលទ្រង់ប្រោសដល់មនុស្សជាតិ (ទំនុកដំកើង១០៧:៣១)។**

យើងអាចចូលរួមច្រៀងបទបន្ទរនេះ ជាមួយនឹងរាស្ត្ររបស់ទ្រង់។ យើងច្រៀង ពីព្រោះយើងត្រូវការចេស្តារបស់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ក្រុមជំនុំរបស់ព្រះជាម្ចាស់សព្វថ្ងៃ ខ្វះចេស្តារបស់ព្រះអង្គខ្លាំងណាស់។ លោកគ្រូគង្វាលមួយរូបនាមថម៉ាស់អខ្វាយណាស់ ចូលទៅក្នុងបន្ទប់មួយដែលពួកចាស់ទុំកំពុងរាប់តង្វាយ។ ពួកចាស់ទុំជម្រាបគ្រូគង្វាលថា "តង្វាយក្រុមជំនុំយើង ទោះចង់ទិញមាស ឬទិញប្រាក់ក៏មិនខ្វះដែរ"។ លោកគ្រូគង្វាលថម៉ាស់ឆ្លើយតបថា "ត្រូវហើយ ក្រុមជំនុំសព្វថ្ងៃពឹងពាក់លើមាសប្រាក់ពេក បានជាមិនអាចបង្គាប់អោយមនុស្សខ្វាក់ភ្លឺភ្នែកបាន!" ក្រុមជំនុំរបស់ព្រះជាម្ចាស់បច្ចុប្បន្ន ខ្វះព្រះចេស្តារបស់ព្រះជាម្ចាស់យ៉ាងខ្លាំងក្រៃលែង ដ្បិតគេទុកចិត្តលើសមត្ថភាពមនុស្ស និងសម្ភារៈដែលគេមាន។

តើក្រុមជំនុំដែលខ្វះព្រះចេស្តាព្រះជាម្ចាស់ ប្រៀបបានទៅនឹងអ្វី? យប់មួយនោះ មានគ្រីស្ទបរិស័ទម្នាក់ទទួលគ្រោះថ្នាក់ដោយរថយន្តបុក។ គេយកគាត់ទៅដាក់មន្ទីរពេទ្យ។ ពេលទៅដល់មន្ទីរពេទ្យ គេត្រូវបញ្ជូនគាត់ទៅមន្ទីរពេទ្យមួយទៀត ដែលនៅឯទីក្រុង។ លុះរៀបចំដើម្បីបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យ អ្នកទទួលខុសត្រូវមន្ទីរពេទ្យប្រាប់អ្នកជម្ងឺថា "យើងមិនដឹងជាតៃកុងបើកឡានពេទ្យសង្គ្រោះទៅឯណាទេ"។ មួយសន្ទុះក្រោយមកឃើញតៃកុងមកដល់។ គាត់និយាយថា "ឡានសង្គ្រោះបន្ទាន់ អស់សាំងយូរណាស់ហើយ"។ ឡានសង្គ្រោះបន្ទាន់អស់សាំង? ក្រុមជំនុំរបស់ព្រះជាម្ចាស់សព្វថ្ងៃ អស់សាំងដែរ។ ក្រុមជំនុំព្រះខ្វះចេស្តារបស់ព្រះជាម្ចាស់។ បើគ្រាន់តែមើលពីក្រៅ ឃើញមានភាពគគ្រឹកគគ្រេងនៅក្នុងក្រុមជំនុំ អគារខ្ពស់ កម្មវិធីថ្វាយបង្គំមាន

លំដាប់លំដោយ ការដើរឃោសនាអួតអាងពូខ្លួនខ្លាំង តែក្រុមជំនុំរបស់ព្រះជាម្ចាស់ខ្វះចេស្ដារបស់ព្រះជាម្ចាស់។ តើអ្វីទៅជាចេស្ដារបស់ព្រះជាម្ចាស់? ចេស្ដារបស់ព្រះជាម្ចាស់ សម្ដែងអោយឃើញក្នុងជីវិតបរិសុទ្ធរបស់អ្នកដែលប្រកាសថា គេជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ បើអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទអួតពីព្រះបន្ទូល តែកិរិយាប្រព្រឹត្តរបស់ខ្លួន តែ១ ស្ករ១ ប៉ះស្រាផឹកស្រា ខ្ទីរបស់គេស៊ីដាច់ ភូតភរអោយឈ្លុយនោះហើយដែលហៅថាអ្នកជឿគ្មានចេស្ដារបស់ព្រះជាម្ចាស់។ ក្រុមជំនុំរបស់ព្រះជាម្ចាស់ ត្រូវការចេស្ដារបស់ព្រះអង្គ។ អ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រប់រូប ត្រូវការចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិត។ តើហេតុអ្វីបានជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ ខ្វះចេស្ដារបស់ព្រះអង្គ? មូលហេតុមួយមកពីគេខ្វះកិរិយាសរសើរតម្កើងដល់ព្រះជាម្ចាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

**គួរឱ្យគេលើកដំកើងទ្រង់នៅក្នុងជំនុំនៃជនទាំងឡាយ ហើយសរសើរទ្រង់នៅទីអង្គុយរបស់ពួកចាស់ទុំដែរ (ទំនុកដំកើង ១០៧:៣២)។**

យើងត្រូវថ្វាយកិរិយាសរសើរដល់ព្រះជាម្ចាស់។ ការថ្វាយកិរិយាសរសើរដល់ព្រះជាម្ចាស់ ជាភ័ស្តុតាងបញ្ជាក់ចេស្ដារបស់ព្រះអង្គ សណ្ឋិតនៅក្នុងជីវិតរបស់យើង។ ប្រៀបឧបមានដូចជាឡានពេទ្យសង្គ្រោះបន្ទាន់ត្រូវការសាំង ក្រុមជំនុំរបស់ព្រះជាម្ចាស់

ត្រូវការចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។

> **បើអ្នកណាមានប្រាជ្ញា នោះនឹងរក្សាទុកនូវសេចក្តីទាំងនេះ ហើយនឹងពិចារណាពីសេចក្តីសប្បុរសរបស់ព្រះយេហូវ៉ា (ទំនុកដំកើង ១០៧:៤៣)។**

ព្រះជាម្ចាស់មានសេចក្តីស្រឡាញ់យ៉ាងសប្បុរសដល់មនុស្ស ជាកម្មសិទ្ធិរបស់ទ្រង់។ សេចក្តីស្រឡាញ់ដ៏សប្បុរសរបស់ទ្រង់ សម្តែងអោយឃើញនៅក្នុងហេតុការណ៍ដែលព្រះអង្គប្រទានដល់យើងនូវអ្វីមួយដែលយើងមិនគួរនឹងទទួល។

# ជំពូក ១០៨

***ឆាកចនា*** *សាសន៍អ៊ីស្រាអែលថ្វាយពាក្យសរសើរដល់ព្រះ ព្រោះទទួលបានមរតកខ្លួនវិញ*

ទំនុកដំកើងជំពូក១០៨ ជាទំនុករបស់ព្រះបាទដាវីឌ។ ព្រះជាម្ចាស់បណ្ដាលអោយហោរារបស់ទ្រង់កត់ត្រាសេចក្ដីទុកដាច់ៗពីគ្នា ពីព្រោះព្រះអង្គមានផែនការរួមសម្រាប់សេចក្ដីដែលព្រះអម្ចាស់ចង់មានបន្ទូលនៅក្នុងជំពូកនេះ។

**ឱព្រះអង្គអើយ ចិត្តទូលបង្គំបានតាំងនៅមាំហើយ ទូលបង្គំនឹងច្រៀង អើ នឹងច្រៀងសរសើរ ដោយសារកិត្តិយសរបស់ទូលបង្គំដែរ (ទំនុកដំកើង១០៨:១)។**

ពួកសេសសល់នៃសាសន៍អ៊ីស្រាអែល ត្រូវរស់ឆ្លងកាត់គ្រាមហាទុក្ខ។ នៅចុងគ្រាមហាទុក្ខ ព្រះជាម្ចាស់រំដោះរាស្ត្រទ្រង់ រួចហើយនាំគេនោះចូលទៅនៅក្នុងទឹកដីសន្យា។ ដោយសារមូលហេតុនេះ បានជាសាសន៍អ៊ីស្រាអែលនាំគ្នាថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់ ព្រោះព្រះអង្គបានប្រទានទឹកដីសន្យាដល់គេសារជាថ្មីម្ដងទៀត។

**ព្រះទ្រង់បានមានបន្ទូល ដោយសេចក្តីបរិសុទ្ធរបស់ទ្រង់ថា យើងនឹងត្រេកអរឡើង ក៏នឹងបែងចែកស្រុកស៊ីគែម ហើយនឹងវាស់ច្រកភ្នំស៊ិកូត (ទំនុកដំកើង១០៨:៧)។**

ខខាងលើ ជាពាក្យសម្តីរបស់សាសន៍អ៊ីស្រាអែល ដែលព្រះជាម្ចាស់បានរំដោះអោយរួចពីគ្រាមហាទុក្ខ។ គេថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់ ពីព្រោះគេបានចូលមកនៅទឹកដីសន្យាម្តងទៀត។ គេចែកភូមិ ចែកស្រុកទៅតាមគ្រួសារ និងត្រកូលរបស់គេ។ ពីពេលនោះទៅ គេទទួលសេចក្តីរីករាយសប្បាយជាមួយនឹងព្រះជាម្ចាស់អស់កល្បជានិច្ចតរៀងទៅ។

# ជំពូក ១០៩

***ធាតុចនា*** *ព្រះគ្រីស្ទទទួលយកសេចក្តីអាម៉ាស់*

ជំពូក១០៩ សម្តែងពីហេតុការណ៍ដែលព្រះអម្ចាស់យេស៊ូវស្ម័គ្រព្រះហឫទ័យព្រមទទួលសេចក្តីអាម៉ាស់ជំនួសមនុស្សមានបាប។ យើងអាចហៅជំពូកនេះថាជាទំនុករៀបរាប់ពីលោកយូដាស-អ៊ីស្ការីយ៉ុតក៏បាន។ នៅក្នុងគម្ពីរកិច្ចការ១:២០ លោកស៊ីម៉ូន-ពេត្រុសបានប្រើជំពូក១០៩ សម្រាប់បរិយាយពីកិរិយាក្បត់របស់លោក យូដាស-អ៊ីស្ការីយ៉ុត។

**[៦]សូមទ្រង់តាំងអ្នកអាក្រក់ឱ្យគ្រប់គ្រងលើវា ហើយឱ្យសាតាំងឈរ**
**នៅខាងស្តាំវា [៧]កាលណាវាត្រូវជំនុំជំរះ នោះសូមឱ្យវាមានទោស**
**ហើយឱ្យសេចក្តីអធិស្ឋានរបស់វាត្រឡប់ជាអំពើបាបវិញ [៨]សូមឱ្យ**
**ថ្ងៃអាយុរបស់វាបានខ្លីចុះ ហើយឱ្យមានម្នាក់ទៀតទទួលយក**
**ការងាររបស់វា [៩]សូមឱ្យកូនចៅវានៅជាកំព្រាឪពុក ហើយ**
**ឱ្យប្រពន្ធវានៅជាមេម៉ាយ (ទំនុកដំកើង១០៩:៦-៩)។**

ខខាងលើ បង្ហើបអោយយើងដឹងថា លោកយូដាស-អ៊ីស្ការីយ៉ុត មាន

ប្រពន្ធនិងមានកូនជាច្រើន។

**សូមឱ្យកូនចៅវាធ្វើជាមនុស្សអាវ៉ាសែទាំងដើរសុំទាន ឱ្យគេរកស៊ីតាមទីច្រកល្ហករបស់គេ (ទំនុកដំកើង១០៩:១០)។**

សេចក្ដីខាងលើ បរិយាយពីលោកយូដាស-អីស្ការីយ៉ុត។ ចំពោះអ្នកជឿពិតដល់ព្រះជាម្ចាស់ គ្មាននរណាមួយយល់ថាកិរិយាប្រព្រឹត្តរបស់លោកយូដាស-អីស្ការីយ៉ុតត្រឹមត្រូវទេ។ បើលោកយូដាស-អីស្ការីយ៉ុតរស់សម័យសព្វថ្ងៃនេះវិញ ពិតជាមានក្រុមមនុស្សប្រកាន់ថា លោកយូដាស-អីស្ការីយ៉ុតជាអ្នកត្រឹមត្រូវ ព្រះអម្ចាស់យេស៊ូវជាអ្នកធ្វើខុស។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានសម្ដែងយ៉ាងច្បាស់ពីវាសនារបស់លោកយូដាស-អីស្ការីយ៉ុត។ លោកយូដាស-អីស្ការីយ៉ុតជាមនុស្សបាត់បង់។ លោកមិនបានទទួលសេចក្ដីសង្គ្រោះទេ។ ព្រះអម្ចាស់យេស៊ូវមានបន្ទូលនៅក្នុងគម្ពីរម៉ាថាយ២៦:២៤ថា "ឯកូនមនុស្សត្រូវទៅមែន តាមសេចក្ដីដែលបានចែងទុកពីដំណើរលោក ប៉ុន្តែវេទនាដល់អ្នកនោះដែលនឹងបញ្ជូនកូនមនុស្សទៅ បើវាមិនបានកើតមក នោះល្អដល់វាជាជាង"។ ឯគម្ពីរយ៉ូហាន៣:៣៦បញ្ជាក់បន្ថែមថា "ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្ដីក្រោធរបស់ព្រះតែងនៅ

ជាប់លើអ្នកនោះឯង”។ បទគម្ពីរទាំងពីរខាងលើសម្ដែងយ៉ាងច្បាស់ថា លោកយូដាស-អ៊ីស្ការីយ៉ុតមិនបានទទួលសេចក្ដីសង្គ្រោះទេ។ ព្រះបន្ទូលសម្ដែងថា សេចក្ដីជំនុំជំរះស្ថិតនៅជាប់ជាមួយនឹងអស់អ្នកដែលមិនទទួលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ដើម្បីអោយបុគ្គលម្នាក់ រួចពីការជំនុំជំរះរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់សុគតជំនួសអំពើបាបរបស់បុគ្គលនោះ។ បីថ្ងៃក្រោយមក ទ្រង់រស់ឡើងវិញ។ អស់អ្នកណាដែលជឿដល់ព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ ពិតជាទទួលបាននូវសេចក្ដីសង្គ្រោះដល់ព្រលឹងរបស់ខ្លួន។ ផ្ទុយទៅវិញ បើមិនព្រមទទួលជឿព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះទេ សេចក្ដីជំនុំជំរះរបស់ព្រះជាម្ចាស់ស្ថិតនៅជាមួយអ្នកនោះ ចាប់ពីគ្រាសម័យសព្វថ្ងៃនេះ រហូតដល់អស់កល្បជានិច្ចតរៀងទៅ។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្ដម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ “ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!”